## ច្បាប់ទប់ស្កាត់អំពើហិង្សា



### តើអ្នកប្រព្រឹត្តអំពើហិង្សាត្រូវទទួលទោសដែរឬទេ ?

**មាត្រា ៣៥**

អំពើហិង្សាក្នុងគ្រួសារទាំងឡាយណា ដែលចូលជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

## តួនាទីយេនឌ័រ



### តើតួនាទីយេនឌ័រគឺជាអ្វី ?

គឺជាតួនាទី ឬ ការងាររបស់បុរស និងស្ត្រីដែលកំណត់ដោយសង្គម។ ឧទាហរណ៍៖ បុរសជាអ្នកដឹកនាំ ស្ត្រីជាអ្នកមើលថែទាំកូន។

## តួនាទីយេនឌ័រ មាន ៣ ប្រភេទ

- តួនាទី/ការងារមានកម្រៃ៖ ការងារកែច្នៃម្ហូបអាហារ ការលក់ដូរស៊ីឈ្នួល អ្នកធ្វើការងារមន្ត្រីរាជការ អ្នកធ្វើការងារអង្គការនានា។
- តួនាទី/ការងារមិនមានកម្រៃ៖ ការងារផ្ទះសម្បែង ចម្អិនម្ហូបអាហារ ថែទាំគ្រួសារ អប់រំកូនចៅ។
- តួនាទី/ការងារសហគមន៍៖ ការងារស្ម័គ្រចិត្ត ដូចជាការចូលរួមលើកផ្លូវលំ ស្តារប្រលាយ ស្តារស្រះសហគមន៍ ចូលរួមការងារអភិវឌ្ឍន៍ក្នុងភូមិ ឃុំ សង្កាត់ និងស្រុក ខណ្ឌ ធ្វើអនាម័យក្នុងភូមិ ធ្វើបុណ្យក្នុងភូមិ។ល។

## ទំនាក់ទំនង និងតម្លៃនៃការងារ៣ ប្រភេទ

**ការងារផ្ទះសម្បែង ជួយបំពេញឲ្យការងារក្រៅផ្ទះ ឬការងាររកប្រាក់ចំណូល**

- ការងារសហគមន៍ បង្កើននូវភាពស្និតស្នាល និងជួយគ្នាទៅវិញទៅមកនៅក្នុងភូមិ ឃុំ
- ការងារទាំង៣ប្រភេទនេះ មានតម្លៃ និងមានសារៈសំខាន់ដូចៗគ្នា និងមានទំនាក់ទំនងគ្នាទៅវិញទៅមកមិនអាចកាត់ផ្តាច់បាន

CHEC

# អង្គការកម្ពុជាដើម្បីសុខភាពនិងការអប់រំសហគមន៍អេក



**មុនចាប់ផ្តើមកិច្ចប្រជុំអ្នកអប់រំត្រូវធ្វើការណែនាំ៖**

១. មតិស្វាគមន៍.................................................

២. បង្ហាញឈ្មោះ..............................................

២. តួនាទី.......................................................

៣. មកពីអង្គការ..............................................

៤. គោលបំណងនៃកិច្ចប្រជុំ...................................

៥. រយៈពេលនៃកិច្ចប្រជុំ......................................

## អំពើហិង្សា



### អំពើហិង្សាគឺជាអ្វី ?

អំពើហិង្សាសំដៅយកការរំលោភបំពាន ឬបង្ខិតបង្ខំផ្លូវចិត្ត ផ្លូវកាយ ផ្លូវភេទ ផ្លូវសេដ្ឋកិច្ច រួមបញ្ចូលទាំងការប្រមាថមាក់ងាយ ការគំរាមគំហែង ការដាក់ឱ្យនៅឯកោដាច់ពីគេឯង និងការរំលោភបំពានផ្នែកជីវភាពសេដ្ឋកិច្ចពីសំណាក់បុគ្គលម្នាក់ ឬច្រើន ដើម្បីត្រួតត្រាទៅលើបុគ្គលផ្សេងៗទៀត។

## ប្រភេទនៃអំពើហិង្សា




### តើអំពើហិង្សាមានប៉ុន្មានប្រភេទ ?

អំពើហិង្សាមាន៤ប្រភេទ

**១. អំពើហិង្សាផ្លូវកាយ មានដូចជា៖** រុញ ច្រាន វាយដំ ទាត់ធាក់ ទះកំផ្លៀង វាយនឹងវត្ថុ គប់នឹងវត្ថុ អំពើផ្សេងទៀតដែលបង្គ្រោះថ្នាក់...។ល។

**២. អពើហិង្សាផ្លូវចិត្ត មានដូចជា៖** អាកប្បកិរិយាមួយចំនួនដូចជា ៖ស្រែក ជេរ ប្រមាថ ធ្វើឲ្យអាម៉ាស់ រិះគន់ គំរាម កំហែង ការប្រើពាក្យអសុរ៉ុះ ...។ល។

**៣. អំពើហិង្សាផ្នែកសេដ្ឋកិច្ច មានដូចជា៖** ៖ការបដិសេធមិនឲ្យដៃគូគ្រប់គ្រងធនធានសំខាន់ៗដូចជា ៖ការមិនផ្តល់ថវិកា បំផ្លិចបំផ្លាញទ្រព្យការមិនជួយផ្នែកហិរញ្ញវត្ថុការបិតសិទ្ធិសេរីភាពក្នុងការរកប្រាប់ចំណូល

**៤. អំពើហិង្សាផ្លូវភេទ មានដូចជា៖** ការបង្ខំឱ្យរួមភេទ ការចាប់រំលោភ បទប្រទូស្តកេរ្តិ៍ខ្មាស ការបង្ខំឱ្យរៀបការ ឬរុកកួនផ្លូវភេទ...។ល។



មូលហេតុអ្វីដែលបង្កអោយមានអំពើហិង្សា?

### មូលហេតុដែលបង្កឱ្យមានអំពើហិង្សា

- ចង់បានអំណាចមកត្រួតត្រាលើសមាជិកក្រុមគ្រួសារ
- ចង់អោយគេគោរពកោតខ្លាច និងធ្វើតាមតម្រូវការរបស់ខ្លួន
- ចង់បង្ហាញថាខ្លួនឯងជាមនុស្សខ្លាំងពូកែ
- ខ្វះវិធីគ្រប់គ្រងកំហឹងខ្លួនឯង
- ខ្វះទឹកចិត្តមេត្តាសណ្តោសប្រណី
- ខ្វះការអត់អោនអាធ្យាស្រ័យ

### កត្តាជំរុញដែលបង្កឱ្យមានអំពើហិង្សា

☞ កត្តាជំរុញគឺជាកត្តាដែលជំរុញឲ្យមានអំពើហិង្សាលើស្ត្រី ឬបង្កើនហានិភ័យនៃអំពើហិង្សាលើស្ត្រី និងជះឥទ្ធិពលលើប្រភេទ និងទំហំនៃអំពើហិង្សាលើស្ត្រីក្នុងគ្រប់មជ្ឈដ្ឋាន។ កត្តាជំរុញមិនបង្កឲ្យមានអំពើហិង្សាលើស្ត្រីឡើយ ទោះបីជាវាពាក់ព័ន្ធនឹងអំពើមួយចំនួននៃការប្រព្រឹត្តអំពើហិង្សាលើស្ត្រីក៏ដោយ។

☞ ការប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹង ជាកត្តាជំរុញ ប៉ុន្តែមិនមែនអ្នកសេពគ្រឿងញៀន ឬគ្រឿងស្រវឹងទាំងអស់សុទ្ធតែវាយប្រពន្ធរបស់ខ្លួន ឬចាប់រំលោភស្ត្រីឡើយ។

☞ ភាពក្រីក្រ អវិជ្ជា ប្រច័ណ្ឌ ...ជាកត្តាជំរុញ ប៉ុន្តែមិនមែនស្ត្រី និងក្មេងស្រីក្រីក្រទាំងអស់សុទ្ធតែទទួលរងការបំពានផ្លូវភេទ ឬត្រូវធ្វើការងារផ្លូវភេទឡើយ។

☞ កត្តាជំរុញជាច្រើនអាចត្រូវបានលុបបំបាត់ ឬកាត់បន្ថយច្រើនតាមរយៈសកម្មភាពទប់ស្កាត់។



### ✎ តើអំពើហិង្សានាំឱ្យមានផលប៉ះពាល់អ្វីខ្លះ ?

- **ផ្លូវកាយ** - របួសស្នាម ពិការ បាត់បង់ជីវិត បាត់បង់ធនធានមនុស្ស
- **ផ្លូវចិត្ត** - ភ័យខ្លាច បាក់ស្បាត អារម្មណ៍មិនហ្នឹងនរ អស់សង្ឃឹម ឡប់សតិ វិកលវិកល អាចធ្វើអត្តឃាត
- **ផ្លូវសេដ្ឋកិច្ច** - ខូចខាតទ្រព្យសម្ភារៈ វិបត្តិជីវភាពគ្រួសារ បង់ខាតលើការចំណាយលើការព្យាបាលរបួស ចំណាយលើការជួសជុល ឬ ទិញរបស់ប្រើប្រាស់
- **ផ្លូវភេទ** - បង្ករការឈឺចាប់ផ្លូវចិត្ត មានភាពភ័យខ្លាច ភាពតក់ស្លុត រស់នៅមិនស្ងប់ អារម្មណ៍មិនល្អ អាចធ្លាក់ទៅក្នុងការជួញដូរផ្លូវភេទ អាចធ្វើអត្តឃាត ឬ ចងគំនុំសងសឹក។

### យេនឌ័រ



### តើយេនឌ័រគឺជាអ្វី ?

- យេនឌ័រ សំដៅដល់លក្ខណៈខុសគ្នាឬទំនាក់រវាងប្រុសនិងស្រី ដែលបង្កើតឡើងដោយសង្គម លក្ខណៈនេះ រួមមានដូចជា តួនាទី, អាកប្បកិរិយា, សកម្មភាព និងលក្ខណៈដទៃទៀត ដែលសង្គមចាត់ទុកជាការសមស្របសម្រាប់មនុស្សប្រុសនិងមនុស្សស្រី។ ប៉ុន្តែយើងអាចផ្លាស់ប្តូរនិងកែប្រែវាបាន

### អំពើហិង្សាយេនឌ័រ




☞ អំពើហិង្សាយេនឌ័រគឺជាអំពើហិង្សាដែលបង្កឡើងលើជនណាម្នាក់ ដោយសារតែយេនឌ័ររបស់ពួកគេ។ ពាក្យយេនឌ័រមិនមែនសំដៅលើភេទរបស់មនុស្សទេ មានន័យថាមិនសំដៅលើតែភេទស្រីនោះទេ ពោលគឺសំដៅទាំងភេទស្រី និងប្រុស និងអ្នកស្រលាញ់ភេទដូចផងដែរ

### សមភាពយេនឌ័រ



### តើសមភាពយេនឌ័រមានន័យដូចម្តេច ?

- សមភាពយេនឌ័រ សំដៅទៅដល់ សិទ្ធិស្មើភាព គ្នា, ការទទួលខុសត្រូវស្មើភាពគ្នា និងឱកាសស្មើភាពគ្នា រវាងស្ត្រីនិងបុរស, ក្មេងប្រុសនិងក្មេងស្រី។
- សមភាព មិនមែន មានន័យថា ស្ត្រីនិងបុរស នឹងមាន លក្ខណៈដូចគ្នានោះទេ ប៉ុន្តែ មានន័យថា សិទ្ធិ ការទទួលខុសត្រូវ និងឱកាស របស់បុរសនិងស្ត្រី នឹងមិនពឹងអាស្រ័យទៅលើការដែលគាត់កើតមកជាប្រុសឬស្រីនោះទេ។
- សមភាពយេនឌ័រ មានន័យថា ផលប្រយោជន៍, តម្រូវការ និងអាទិភាព របស់បុរសនិងស្ត្រី ត្រូវបានយកមកពិចារណាតាមរយៈការទទួលស្គាល់ភាពចម្រុះនៃក្រុមផ្សេងៗរបស់បុរសនិងស្ត្រី។ សមភាពយេនឌ័រ មិនមែនជាបញ្ហារបស់ស្ត្រីនោះទេ ប៉ុន្តែ គួរមានទាក់ទងនិងចូលរួមដោយពេញលេញពីបុរស ក៏ដូចជាពីស្ត្រី។